រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៩

សេចក្តីសម្រេចលេខ ២៦ ស.ស.រ

ស្តីពីការផ្តល់ប្រាក់លើកជូនមន្ត្រីរាជការ ក្រុងប៉ៃលិន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៦/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៧៩៧/១៩៩ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតក្រុងប៉ៃលិន

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញលិខិតលេខ ៧៩៩ សជណ.ផក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការក្រុងប៉ៃលិន

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

ប្រការ ១ : ត្រូវបានផ្តល់ប្រាក់លើកជូនមន្ត្រីរាជការក្រុងប៉ៃលិន ដែលរាជរដ្ឋាភិបាលបានអនុញ្ញាត បញ្ចូលក្នុងក្របខ័ណ្ឌ ដោយគិតប្រាក់លើកនេះ ចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៧ តទៅ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងចៅហ្វាយក្រុងប៉ៃលិន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត **ហ៊ុន សែន**

★★★